- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

មាត្រា ១ ._ តែងតាំងលោក ឆុង ឌឹន បច្ចុប្បន្នកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំក្រុងហុងកុងជាអគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំក្រុងហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែមេសា ឆ្នាំ១៩៩៩

### សេចក្តីសំរេចលេខ ៣៣ សសរ

### ស្តីពីការបង្កើតគណៈកម្មការទេចខ្ទប់ និងដឹកជញ្ជូនសំណល់ប្លាស្ទិកចំនួន ៦៥០ តោន ចេញពីព្រះរាជាណាចក្រកម្ពុជា

***

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- យោងអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន

## សំរេច

**ប្រការ ១ ៖** ត្រូវបានបង្កើតគណៈកម្មការវេចខ្ចប់ និងដឹកជញ្ជូនសំណល់ប្លាស្ទិចចំនួន ៦៥០ តោន ចេញពីព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាព ៖

១- ឯកឧត្តម នាន់ សាផាន់ រដ្ឋលេខាធិការក្រសួងបរិស្ថាន ប្រធាន

២- លោក ហេង សុខុម អនុប្រធាននាយកដ្ឋានកាកុងត្រូល អនុប្រធាន

៣- លោក ឡាយ ឫទ្ធី នាយករង ទីចាត់ការគយ និងរដ្ឋាករ សមាជិក

៤- លោក លូ គីមឈុន ប្រធានកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ សមាជិក

៥- លោក គាំង លាងខណ្ឌ អនុប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក ។

**ប្រការ ២ ៖** គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម ៖

- ទទួលខុសត្រូវតាមដាន ត្រួតពិនិត្យនូវរាល់សកម្មភាពវេចខ្ចប់ឡើងវិញ និងការដឹកជញ្ជូនសំណល់ ចេញពីព្រះរាជាណាចក្រកម្ពុជា របស់ភាគីក្លូអ៊ី ។
- ទទួលខុសត្រូវសំរបសំរួលរៀបចំសំណុំលិខិត និងអាជ្ញាប័ណ្ណនាំចេញជូន ដល់ភាគីក្លូអ៊ី ។

**ប្រការ ៣ ៖** អភិបាលក្រុងព្រះសីហនុ ត្រូវសហការ និងសំរបសំរួលជាមួយគណៈកម្មការនេះបំពេញភារកិច្ចអោយបានល្អ និងប្រកបដោយសុវត្ថិភាព ។

**ប្រការ ៤ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលក្រុងព្រះសីហនុ កំពង់ផែក្រុងព្រះសីហនុព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស ខេង

***

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៣៤ សសរ

## ស្តីពីការបង្កើតគណៈកម្មាធិការពិនិត្យវាយតម្លៃ

## សញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា